

# "ការរៀបចំឬល្បួងលោម" តាមបណ្តាញអ៊ីនធឺណិត

## និយមន័យ

### "ការរៀបចំឬល្បួងលោម" តាមបណ្តាញអ៊ីនធឺណិត

"ការរៀបចំឬល្បួងលោម" តាមបណ្តាញអ៊ីនធឺណិត ជាដំណើរការនៃការបង្កើតឱ្យមានការប្រាស័យទាក់ទងគ្នាជាមួយកុមារតាមអ៊ីនធឺណិត ដោយមានគោបំណងដើម្បីទាក់ទាញចិត្ត សម្របសម្រួល ឬជម្រុញលើកទឹកចិត្តកុមារឲ្យពាក់ព័ន្ធនឹងសកម្មភាពផ្លូវភេទ។

សកម្មភាពផ្លូវភេទទាំងនោះ រួមសកម្មភាពមុនពេលការជួបជាក់ស្តែងជាមួយជនល្មើស ដូចជាការរំលោភបំពានផ្លូវភេទកុមារតាមវែបខេម (webcam) ឬការផលិតរូបភាព និងសម្ភារៈអាសអាភាសកុមារ ឬរូបភាព និងសម្ភារៈអាសអាភាសដែលកុមារផលិតដោយខ្លួនឯង ។

### គោលការណ៍ច្បាប់




"ការរៀបចំឬល្បួងលោម" ត្រូវបានចាត់ជាបទល្មើសព្រហ្មទណ្ឌក្នុងអនុសញ្ញាឡានហ្សារ៉ូត (Lanzarote Convention)។

<u>អនុសញ្ញាឡានហ្សារ៉ូត (Lanzarote Convention)</u> មានមាត្រា (23) ស្តីពី អំពើស្នើសុំ ឬបបួលកុមារឱ្យជួបជនល្មើសក្នុងគោលបំណងផលិតរូបភាព និងសម្ភារៈអាសអាភាសកុមារ។ បន្ថែមលើនេះ វាក៏ចាត់ជាបទល្មើសព្រហ្មទណ្ឌផងដែរចំពោះ អំពើកេងចំណេញលើកុមារ ឬសកម្មភាពឲ្យកុមារមើលសកម្មភាពរំលោភបំពាន ឬសកម្មភាពផ្លូវភេទផ្សេងៗ (មាត្រា ២២)។

លើសពីនេះ <u>អនុសញ្ញាស្តីពីបទល្មើសលើអ៊ីនធឺណិតរបស់សហគមន៍អាហ្វ្រិកនិងការការពារទិន្នន័យ</u> (មិនទាន់អនុវត្តនៅឡើយ) បានចាត់ជាបទល្មើសព្រហ្មទណ្ឌផងដែរនូវសកម្មភាពសម្របសម្រួល ឬអនុញ្ញាតឲ្យអនីតិជនមើលរូបភាព និងសម្ភារៈអាសអាភាស។ មាត្រានេះ (29)(3)(1)(d) ក៏បានចែងផងដែរអំពីធាតុសំខាន់ៗនៃការរៀបចំឬល្បួងលោម។

### អ្នកប្រព្រឹត្តបទល្មើស និងវិធីប្រតិបត្តិការរបស់ពួកគេ

- ជនល្មើសត្រូវបានជំរុញដោយ  ចំណង់ផ្លូវភេទរបស់ពួកគេ ចំពោះកុមារ ឬដោយ**ទទួលបានប្រយោជន៍ហិរញ្ញវត្ថុ**
- ជនល្មើស ធ្វើសកម្មភា**ពតែម្នាក់ឯង** ឬជាផ្នែកនៃ**បណ្តាញ**;
- ជនល្មើស ផ្តោតលើជនរងគ្រោះតាមរយៈ **ការប៉ាន់ប្រមាណលើភាពងាយរងគ្រោះរបស់ពួកគេ** (ឧទាហរណ៍ការទុកចិត្តខ្លួនឯង ការគ្រប់គ្រងពីឪពុកម្តាយ);
- **ការទាក់ទង**ជាមួយកុមារ ជាទូទៅត្រូវបានចាប់ផ្តើមលើ**អ៊ីនធឺណិត** ឧទាហរណ៍កម្មវិធីបន្ទប់ជជែកកំសាន្ត (chatrooms) គេហទំព័រហ្គេមផ្សេងៗ ឬគេហទំព័រ និងកម្មវិធីបណ្តាញសង្គមនានា  ប៉ុន្តែ "ការរៀបចំឬល្បួងលោមជាក់ស្តែងក្នុងជីវិតពិតក៏កើតមានផងដែរ។
- តាមធម្មតា "ការរៀបចំឬល្បួងលោម" ពាក់ព័ន្ធនឹងការបង្កើត**ទំនាក់ទំនងផ្នែកអារម្មណ៍ជា**មួយកុមារដើម្បីទទួលបានការទុកចិត្តរបស់កុមារ;
- ពេលខ្លះជនល្មើស ក៏ "**រៀបចំឬល្បួងលោមបុគ្គលផ្សេងទៀតផងដែរ** ដូចជាមិត្តភ័ក្តរបស់កុមារ ក្រុមគ្រួសារ និងសហគមន៍ទាំងមូលផងដែរ;
- ចរិកលក្ខណៈនៃ ការរៀបចំឬល្បួងលោម "**ការរៀបចំឬល្បួងលោម**" > រួមមានការបំពេញតម្រូវការរបស់កុមារ តាមរយៈការផ្តល់ជូនការយកចិត្តចិត្តទុកដាក់ និងរង្វាន់, ការបង្ខិតបង្ខំផ្លូវចិត្ត ការពន្យល់ល្បួងលោម ការចង់បង្រៀនកុមារពីរឿងផ្លូវភេទ និងការផ្សាំកុមារទៅនឹងសកម្មភាពផ្លូវភេទ។;
- ជនបទល្មើស អាច**ក្លែងខ្លួនជាអ្នកណាម្នាក់ទៀត** ដើម្បីធ្វើឲ្យកុមារពាក់ព័ន្ធនឹងទំនាក់ទំនង (ផ្លូវភេទ);
- ជនល្មើសបង្កើន  **សកម្មភាពផ្លូវភេទក្នុងទំនាក់ទំនង** ជាមួយកុមារ;
- ជនល្មើស ជាទូទៅប្រើប្រាស់**ការបំបែកឱ្យនៅដាច់ដោយឡែក ការសម្ងាត់ ការស្តីបន្ទោស** ដើម្បីបន្តឲ្យកុមារចូលរួមក្នុងសកម្មភាពផ្លូវភេទ និងរក្សាភាពស្ងៀមស្ងាត់។

## តើលោកអ្នកអាចធ្វើអ្វីខ្លះបាន?

- តស៊ូមតិដើម្បីឲ្យមានគោលការណ៍ច្បាប់ដែលរឹងមាំ ដែលចាត់រាល់សកម្មភាពការល្បួងលោមលើអ៊ីនធឺណិតជាបទល្មើសព្រហ្មទណ្ឌ។
- តស៊ូមតិដើម្បីឲ្យមានធនធានដែលប្រសើរជាងមុន សម្រាប់មន្ត្រីអនុវត្តច្បាប់ ដូចជា សមត្ថភាពនិងវិធីសាស្ត្រប្រកបដោយការប្តេជ្ញាចិត្ត ដើម្បីដោះស្រាយបញ្ហា "ការរៀបចំឬល្បួងលោម" លើអ៊ីនធឺណិត
- តស៊ូមតិ និងសហការជាមួយអង្គភាពហិរញ្ញវត្ថុឯកជន ដូចជាក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត ដើម្បីអនុវត្តវិធានការនានា ដើម្បីផ្តល់ជូននូវបរិយាកាសប្រកបដោយសុវត្ថិភាពលើបណ្តាញអ៊ីនធឺណិត។
- អប់រំ និងបង្កើនការយល់ដឹងអំពី "ការរៀបចំឬល្បួងលោម"
- អនុវត្តការស្រាវជ្រាវ និងប្រមូលព័ត៌មានពាក់ព័ន្ធ ដើម្បីពង្រីកការយល់ដឹងអំពីបញ្ហានៃ "ការរៀបចំឬល្បួងលោម" តាមបណ្តាញអ៊ីនធឺណិត
- សូមរាយការណ៍នៅពេលលោកអ្នកដឹងអំពីស្ថានភាពដែលកុមារត្រូវបានគេដាក់ជាគោលដៅនៃការ"ការរៀបចំឬល្បួងលោម" តាមបណ្តាញអ៊ីនធឺណិត
- ផ្តល់ជូនជំនួយគាំទ្រ និងការថែទាំជនរងគ្រោះ។

តារាងព័ត៌មានស្តីអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារលើអ៊ីនធឺណិតនេះផលិតដោយអង្គការ ECPAT អន្តរជាតិ។
ឧបត្ថម្ភគាំទ្រសម្រាប់ការបកប្រែភាសា និងផលិតកម្ម ដែលបានផ្តល់ជូនដោយអង្គការ UNICEF។